

ការដើរតាមគំរូព្រះយេស៊ូវ



ការបង្រៀនតាមរយៈសំបុត្រ
ដោយ ដេរេក ព្រីនស៍

កាតព្វកិច្ចរបស់ក្រុមជំនុំក្នុងសម័យបច្ចុប្បន្ន គឺការប្រកាសដំណឹងល្អទៅកាន់មនុស្សគ្រប់ជាតិសាសន៍នៅទូទាំងពិភពលោក ដែលមើលទៅហាក់ដូចជាបេសកកម្មមួយដ៏លំបាកមិនអាចសម្រេចបាន។ នៅក្នុងកេរដំណែលនៃការបង្រៀន ដែលដកស្រង់ចេញពីសៀវភៅតូចរបស់លោក ដេរេក ព្រីនស៍ មានចំណងជើងថា ព្រះរាជ្យបញ្ជាចុងក្រោយរបស់ព្រះគ្រីស្ទ លោកបានប្រៀបធៀបបេសកកម្មនេះ ទៅនឹងពេលដែលព្រះយេស៊ូវបានធ្វើការអស្ចារ្យក្នុងការផ្តល់អាហារដល់មនុស្សជាច្រើន។ ចំណុចសំខាន់ដែលលោកចង់បញ្ជាក់គឺ៖ យើងអាចជោគជ័យបាន លុះត្រាតែយើងធ្វើតាមគំរូរបស់ព្រះយេស៊ូវ។

> នោះទ្រង់ក៏ប្រាប់ឲ្យហ្វូងមនុស្សអង្គុយទៅដី រួចទ្រង់យកនំប៉័ង៧ នឹងត្រីទាំងនោះមកអរព្រះគុណ ហើយកាច់ប្រទានដល់ពួកសិស្ស គេក៏ចែកដល់ហ្វូងមនុស្ស គ្រប់គ្នាបានបរិភោគឆ្អែត ហើយគេប្រមូលចំណិតដែលនៅសល់ ដាក់ពេញបាន៧កំប្រោង ឯពួកប្រុសៗដែលបានបរិភោគឆ្អែត នោះមាន៤ពាន់នាក់ឥតរាប់ស្រីៗ ហើយនឹងកូនក្មេងផងទេ។ (ម៉ាថាយ 15:32-39)

តើយើងអាចរៀនអ្វីខ្លះពីព្រឹត្តិការណ៍ ដែលព្រះយេស៊ូវបានផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់ និងបួនពាន់នាក់?

ខ្ញុំចង់យកបញ្ហាប្រឈមនៃការផ្តល់អាហារដល់មនុស្សមួយហ្វូងធំ ដែលមានប្រហែល មួយម៉ឺននាក់ ឬ ប្រាំបីពាន់នាក់ ដោយមានអាហារតិចតួចប៉ុណ្ណោះ ធ្វើជាគំរូសម្រាប់យើង។ ជាក់ស្តែង វាជារូបភាពស្របគ្នានឹងបញ្ហាប្រឈមដែលក្រុមជំនុំកំពុងប្រឈម គឺ ការប្រកាសដំណឹងល្អទៅកាន់ពិភពលោកដែលមានប្រជាជនជាងប្រាំពីរពាន់លាននាក់។

កិច្ចការដែលមិនអាចធ្វើទៅបាន?

ច្បាស់ណាស់ យើងត្រូវតែទទួលស្គាល់ថា អ្វីដែលព្រះយេស៊ូវបានបង្គាប់ឲ្យពួកសិស្សធ្វើ គឺមិនអាចទៅរួចទាល់តែសោះ។ ពួកគេគ្មានសមត្ថភាព ឬមធ្យោបាយតាមធម្មជាតិណាមួយ ដើម្បីធ្វើអ្វីដែលទ្រង់បានបង្គាប់ពួកគេនោះឡើយ។ ប៉ុន្តែទ្រង់នៅតែតម្រូវឲ្យពួកគេធ្វើវា។

បើនិយាយតាមភាសាគណិតវិទ្យា ប្រសិនបើខ្ញុំប្រៀបធៀប ភាពមិនអាចទៅរួចនៃការផ្តល់អាហារដល់មនុស្សមួយម៉ឺននាក់ដោយនំប៉័ងប្រាំដុំ និងត្រីពីរក្បាល ជាមួយនឹងភាពមិនអាចទៅរួចនៃការប្រកាសដំណឹងល្អទៅកាន់ពិភពលោកទាំងមូលនៅសព្វថ្ងៃនេះ ខ្ញុំត្រូវតែនិយាយថា ភាពមិនអាចទៅរួចទីមួយ គឺធំជាងភាពមិនអាចទៅរួចទីពីរ។

ផ្ទុយទៅវិញ ដោយពិចារណាពីស្ថានភាពពិភពលោកសព្វថ្ងៃនេះ ជាមួយនឹងមធ្យោបាយទំនាក់ទំនង និងការធ្វើដំណើរទំនើប ព្រមទាំងធនធានដែលមានសម្រាប់ក្រុមជំនុំ ការប្រកាសដំណឹងល្អទៅកាន់ពិភពលោកទាំងមូល មិនមែនជារឿងដែលមិនអាចធ្វើទៅរួចទាំងស្រុងនោះទេ។ ប៉ុន្តែ វាពិតជាកិច្ចការដ៏ធំមហិមាមួយ។

នៅក្នុងសារនេះ ខ្ញុំចង់ធ្វើការប្រៀបធៀបទាំងពីរនេះ ហើយអនុវត្តមេរៀនសាមញ្ញៗមួយចំនួនសម្រាប់ជាប្រយោជន៍ដល់យើង។ មេរៀនទាំងនេះទាក់ទងនឹងភារកិច្ច

របស់យើង ក្នុងការនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូល ទៅកាន់គ្រប់ជាតិសាសន៍ ទៅកាន់មនុស្សគ្រប់រូប និងដល់ចុងបំផុតនៃផែនដី។ ពីក្នុងកំណត់ហេតុនៃការអស្ចារ្យទាំងពីរនេះ ខ្ញុំចង់ដកស្រង់គោលការណ៍សាមញ្ញៗចំនួនប្រាំ។

១. កុំគេចវេសពីការទទួលខុសត្រូវ

ជាដំបូង នៅពេលដែលយើងអានកំណត់ហេតុនៃការផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់ នៅក្នុងដំណឹងល្អរបស់លោកម៉ាថាយ យើងឃើញយ៉ាងច្បាស់ថា ពួកសិស្សមិនចង់ទទួលខុសត្រូវ ក្នុងការផ្តល់អាហារដល់មនុស្សយ៉ាងច្រើននោះទេ។

ទោះជាយ៉ាងណាក៏ដោយ សូមយើងកត់សម្គាល់ពីរបៀបដែលព្រះយេស៊ូវបានមើលឃើញការទទួលខុសត្រូវនោះ។ នេះគឺជាអ្វីដែលព្រះយេស៊ូវ មានបន្ទូលទៅកាន់ពួកសិស្សរបស់ព្រះអង្គ៖ “ចូរអ្នករាល់គ្នាឲ្យគេបរិភោគទៅ”។ ខ្ញុំជឿថា គោលការណ៍ដូចគ្នានេះ គឺពិតប្រាកដសម្រាប់ពួកជំនុំនៅសព្វថ្ងៃនេះផងដែរ។ យើងក៏ប្រហែលជាចង់គេចវេសពីការទទួលខុសត្រូវក្នុងការនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូលដែរ។ ប៉ុន្តែ ព្រះយេស៊ូវមានបន្ទូលដូចគ្នានេះថា៖ “នេះគឺជាការងាររបស់អ្នក។ នេះគឺជាការទទួលខុសត្រូវរបស់អ្នក។ ខ្ញុំបានបង្គាប់ឲ្យអ្នកធ្វើវា។ ហើយខ្ញុំមិនដែលដកបញ្ជានោះវិញឡើយ”។

២. ចូរប្រើទាំងអ្វីដែលជាធម្មជាតិ និងអ្វីដែលអស្ចារ្យលើសពីធម្មជាតិ

ទីពីរ មានធាតុសំខាន់ពីរដែលខ្ញុំចង់បង្ហាញជាឧទាហរណ៍ ពីការផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់ និងបួនពាន់នាក់។ ការអស្ចារ្យទាំងនោះបង្ហាញពីទំនាក់ទំនងដ៏សំខាន់មួយរវាងគោលគំនិតពីរ ដែលគ្រីស្ទបរិស័ទខ្លះតែងតែចាត់ទុកថាស្ទើរតែផ្ទុយគ្នា។ មួយគឺជាសណ្តាប់ធ្នាប់ ឬវិន័យ។ មួយទៀត គឺជាព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះ។

ក្រុមជំនុំខ្លះមានទំនោរផ្តោតសំខាន់ទៅលើមួយ ឬមួយទៀត។ មានក្រុមដែលផ្តោតលើសណ្តាប់ធ្នាប់ និងវិន័យ។ មនុស្សគ្រប់គ្នាត្រូវតម្រៀបជាជួរ មនុស្សគ្រប់គ្នាមានអ្នកដឹកនាំផ្ទាល់ខ្លួន មនុស្សគ្រប់គ្នាត្រូវទទួលខុសត្រូវ មនុស្សគ្រប់គ្នាធ្វើតាមអ្វីដែលខ្លួនត្រូវធ្វើ ហើយមនុស្សគ្រប់គ្នាស្ថិតនៅកន្លែងត្រឹមត្រូវរបស់ខ្លួន។

នោះមិនមែនជារឿងខុសឆ្គងនោះទេ។ ជាក់ស្តែង វាត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងការផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់។

> ទ្រង់មានបន្ទូលទៅពួកសិស្សថា “ចូរឲ្យគេអង្គុយដោយជួរៗទៅក្នុង១ជួរ៥០នាក់”។ (លូកា 9:14ខ)

បើទ្រង់មិនបានធ្វើដូច្នោះទេ មនុស្សខ្លះនឹងមិនបានទទួលអាហារឡើយ។ ដូច្នេះវាចាំបាច់ណាស់ដែលពួកសិស្សចាប់ផ្តើមដោយមានសណ្តាប់ធ្នាប់ ពោលគឺរៀបចំមនុស្សគ្រប់គ្នា ជាក្រុមដែលមានទំហំសមរម្យ ដើម្បីងាយស្រួលក្នុងការបម្រើ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំចង់បញ្ជាក់ថា ពួកគេអាចរៀបចំមនុស្សគ្រប់គ្នាឲ្យមានរបៀបរៀបរយជាក្រុមៗហាសិបនាក់ ហើយទុកឲ្យពួកគេនៅតែឃ្លានបាន! តើការរៀបចំបែបនោះមានប្រយោជន៍អ្វី? សណ្តាប់ធ្នាប់តែមួយមុខ មិនគ្រប់គ្រាន់ទេ។ ដើម្បីឲ្យសណ្តាប់ធ្នាប់នោះមានប្រសិទ្ធភាពត្រូវតែមាន ព្រះគុណ និងព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះ។ អំណាចនៃការអស្ចារ្យនៅក្នុងការបម្រើព្រះអម្ចាស់ មិនមែនជាជម្រើសទេ ប៉ុន្តែជាការចាំបាច់។

នេះគឺជាអ្វីដែលខ្ញុំចង់លើកយកមកធ្វើ ជាគោលការណ៍ទីពីរសម្រាប់យើង។ ដើម្បីឲ្យការអស្ចារ្យអាចកើតឡើងបាន សណ្តាប់ធ្នាប់ និងវិន័យ ត្រូវតែមានតុល្យភាព និងត្រូវបានបំពេញបន្ថែម ដោយអំណាចនៃការអស្ចារ្យរបស់ព្រះជាម្ចាស់។

៣. ចែករំលែកព្រះពរ

គោលការណ៍ទីបីនៃការអស្ចារ្យក្នុងការផ្តល់អាហារដល់មនុស្សជាច្រើននោះគឺថា ការកើនឡើងទ្វេដង មិនអាស្រ័យតែលើព្រះយេស៊ូវប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ វាអាស្រ័យលើការដែលពួកសិស្សបានបន្តចែករំលែកអ្វីដែលពួកគេបានទទួលពីព្រះយេស៊ូវ។ បើពួកសិស្សមិនបានបន្តចែកអ្វីដែលពួកគេបានទទួលទេ នោះការអស្ចារ្យនោះនឹងមិនបានសម្រេចឡើយ។

ជាថ្មីម្តងទៀត ខ្ញុំជឿថា រឿងនេះក៏ពិតដូចគ្នា ចំពោះអ្នក និងខ្ញុំ ទាក់ទងនឹងព្រះគុណរបស់ព្រះ។ វាមិនពឹងផ្អែកតែលើព្រះយេស៊ូវប៉ុណ្ណោះទេ។ វាមានប្រភពចេញពីព្រះយេស៊ូវ ប៉ុន្តែវាត្រូវតែបានបំពេញឲ្យសម្រេចដោយកិច្চសហការ និងសកម្មភាពរបស់យើង។

៤. ចូលទៅក្នុងភាពបរិបូរណ៍

គោលការណ៍ទីបួនដែលខ្ញុំមើលឃើញនៅក្នុងការអស្ចារ្យនៃការផ្តល់អាហារដល់មនុស្សជាច្រើននេះ គឺថា ការកើនឡើងទ្វេដង បានបន្តរហូតដល់តម្រូវការទាំងអស់ត្រូវបានបំពេញ ហើយលើសពីគ្រប់គ្រាន់ទៀតផង។

ច្បាស់ណាស់ មនុស្សគ្រប់គ្នាបានបរិភោគឆ្អែត។ ប៉ុន្តែលើសពីនោះទៀត បន្ទាប់ពីមនុស្សគ្រប់គ្នាបានបរិភោគឆ្អែតហើយ នៅសល់អាហារជាច្រើនទៀត។ នៅចុងបញ្ចប់មានច្រើនជាងនៅពេលចាប់ផ្តើម។ នេះមិនមែនជារឿងចៃដន្យទេ។

នៅក្នុងការអស្ចារ្យទាំងនេះ ខ្ញុំជឿថា ព្រះយេស៊ូវកំពុងបង្ហាញថាធនធានរបស់ព្រះគ្មានដែនកំណត់ឡើយ។ ទ្រង់មិនដែលមានកម្រិតត្រឹមតែបំពេញតម្រូវការប៉ុណ្ណោះទេ ប៉ុន្តែទ្រង់តែងតែមានភាពបរិបូរណ៍។

ព្រះតែងតែមានលើសពីគ្រប់គ្រាន់ជានិច្ច។ តាមការយល់ដឹងរបស់ខ្ញុំអំពីបទគម្ពីរ ទ្រង់តែងតែសព្វព្រះទ័យប្រទានឲ្យយើងនូវអ្វីដែលលើសពីគ្រប់គ្រាន់។

៥. ទទួលបទពិសោធន៍ពីភាពលើសលប់

ចំណុចចុងក្រោយដែលខ្ញុំចង់ដកស្រង់ពីការអស្ចារ្យទាំងនេះគឺថា៖ តម្រូវការកាន់តែធំ ហើយធនធានកាន់តែតិច នោះភាពសម្បូរហូរហៀរដែលអ្នកនឹងទទួលបទពិសោធន៍ក៏កាន់តែច្រើនដែរ។

នេះគឺជាស្ថិតិដែលបង្ហាញពីរឿងនេះ។ នៅក្នុងការអស្ចារ្យដំបូង ចំនួនមនុស្សដែលត្រូវបានទទួលការផ្តល់អាហារឲ្យមានចំនួនច្រើនជាង ប៉ុន្តែ ធនធានដែលពួកគេមានពេលចាប់ផ្តើម គឺតិចជាង។

ពួកគេប្រមូលបានកន្ត្រកដប់ពីរពេញដោយបំណែកអាហារដែលនៅសល់។ នៅក្នុងការអស្ចារ្យទីពីរ ពួកគេនៅសល់ប្រាំពីរកន្ត្រក។

ហេតុអ្វីបានជាព្រះយេស៊ូវទទូចឲ្យប្រមូលបំណែកអាហារដែលនៅសល់ទាំងនោះ? ខ្ញុំជឿជាក់ថា ទ្រង់កំពុងសង្កត់ធ្ងន់លើគោលការណ៍ទីប្រាំដែលបានបង្ហាញក្នុងតាមរយៈការអស្ចារ្យទាំងនេះ។ សូមយើងនិយាយម្តងទៀត៖ តម្រូវការកាន់តែធំ ហើយធនធានកាន់តែតិច នោះភាពសម្បូរហូរហៀរកាន់តែច្រើនដែរ។ ព្រះតែងតែធ្វើឲ្យយើងដឹងថា នៅក្នុងទ្រង់ មិនដែលមានការខ្វះខាតឡើយ។

ការអធិស្ឋានសុំការអស្ចារ្យ

ដោយពិចារណាពីគំរូនៃការអស្ចារ្យដែលព្រះយេស៊ូវបានបង្ហាញដល់យើង និងការរំពឹងទុករបស់ទ្រង់ឲ្យយើងបំពេញការទទួលខុសត្រូវដ៏ធំធេងក្នុងការផ្សាយដំណឹងល្អទៅកាន់ពិភពលោកទាំងមូល ការឆ្លើយតបតែមួយគត់របស់យើង គឺការអធិស្ឋាន។ សូមឲ្យយើងបញ្ចប់ដោយការអធិស្ឋានដ៏សាមញ្ញខាងក្រោមនេះ។

ឱព្រះអម្ចាស់យេស៊ូវអើយ! ទូលបង្គំស្តាប់បង្គាប់តាមព្រះរាជ្យបញ្ជារបស់ព្រះអង្គ ក្នុងការផ្សាយដំណឹងល្អទៅកាន់ពិភពលោកទាំងមូល។ ទូលបង្គំដឹងថា កិច្ចការនេះ ត្រូវការការអស្ចារ្យ ហើយទូលបង្គំឈានចូលដោយសេចក្តីជំនឿ នៅក្នុងចម្លើយដ៏អស្ចារ្យរបស់ទ្រង់ សម្រាប់បញ្ហាប្រឈមនេះ។អាម៉ែន!

ការបង្រៀនតាមរយៈសំបុត្រ
ប្រតិចារិក: TL-L163-100-KHM
បច្ចុប្បន្នភាពចុងក្រោយ: 12 Nov 2026
គេហទំព័រ: Derekprince.com/km/resources

